ចាប់ពី ថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខានេះតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥

**អនុក្រឹត្យលេខ ៦២ អនក្រ.បក**

ស្តីពីការគ្រប់គ្រងការប្រើប្រាស់អាវុធ

និង ជាតិផ្ទុះគ្រប់ប្រភេទ

* * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយ ប្រើតាមព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ ស្តីពីការផ្តន្ទាទោស ការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជា ដែលប្រកាសអោយប្រើដោយក្រឹត្យលេខ ១១ ក្រ ចុះ ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

## ជំពូកទី ១

បទបញ្ញត្តិទូទៅ

**មាត្រា ១ :** អនុក្រឹត្យនេះ មានគោលដៅបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះគ្រប់ប្រភេទ ទូទាំងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២** : ក្រសួងការពារជាតិ មានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រងការប្រើប្រាស់អាវុធ និងជាតិផ្ទុះ ក្នុងកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល

**មាត្រា ៣** : ក្រសួងមហាផ្ទៃ មានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រងការប្រើប្រាស់អាវុធ និង ជាតិផ្ទុះ ក្នុងកងកំលាំងនគរបាលជាតិ និង ជនស៊ីវិល ដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤** : ជនណាកាន់អាវុធដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសតាមមាត្រា ២ មាត្រា ៣ មាត្រា ៤ និង មាត្រា ៥ នៃច្បាប់ស្តីពីការផ្តន្ទាទោសការកាន់អាវុធ និង ការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ញា ដែលប្រកាសអោយប្រើដោយក្រឹត្យ លេខ ១១ ក្រ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ។

## ជំពូកទី ២

### អំពីសមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាត អោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះ

**មាត្រា ៥** : ក្រសួងការពារជាតិ មានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង កងជីវពល ។

**មាត្រា ៦** : ក្រសួងមហាផ្ទៃ មានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះចំពោះនគរបាលជាតិ និង ជនស៊ីវិល ។

**មាត្រា ៧** : ល័ក្ខខ័ណ្ឌនៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និងជាតិផ្ទុះសំរាប់កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងជីវពល កងកំលាំងនគរបាលជាតិ និងជនស៊ីវិល ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់សហរដ្ឋមន្ត្រីក្រសួង ការពារជាតិ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

### សិទ្ធិប្រើប្រាស់អាវុធជាលក្ខណៈបុគ្គល

**មាត្រា ៨** : មន្ត្រីរាជការស្ថាប័នស៊ីវិល ដែលអាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លី ជាលក្ខណៈបុគ្គលបានក្នុងពេលបំពេញបេសកកម្មតាមការកំណត់ថ្នាក់ដូចខាងក្រោម ÷

- នៅក្រសួង ស្ថាប័ន ចាប់ពីថ្នាក់នាយកដ្ឋានឡើងទៅ ។
- នៅខេត្ត ក្រុង រាជធានីភ្នំពេញ ចាប់ពីថ្នាក់អភិបាលរងខេត្ត ក្រុងឡើង

និងទៅ ក្រសួងជុំវិញខេត្ត ក្រុង ។

- នៅខណ្ឌ ស្រុក គឺ អភិបាល និង អភិបាលរង ស្រុក ខណ្ឌ ។ ក្រៅពីបំពេញបេសកកម្ម ត្រូវរក្សាទុកនៅផ្ទះ ។

**មាត្រា ៩ :** កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និង នគរបាលជាតិ អាចអនុញ្ញាតអោយប្រើប្រាស់អាវុធខ្លីជាលក្ខណៈបុគ្គលបាន ក្នុងពេលបំពេញបេសកកម្មតាមការកំណត់ថ្នាក់ដូចខាងក្រោម ÷

- អ្នកមានឋានៈ មុខងារ ចាប់ពីថ្នាក់អនុប្រធានការិយាល័យ និង ថ្នាក់អនុប្រធាន កងអនុសេនាតូចឡើងទៅ ។
- យុទ្ធជន ភ្នាក់ងារ ដែលទទួលបទបញ្ជាអោយទៅបំពេញភារកិច្ចការពារថ្នាក់ដឹកនាំ ឬ អោយទៅបំពេញបេសកកម្មជំនាញនៅតំបន់អសន្តិសុខ ក្រៅពីបំពេញបេសកកម្ម ត្រូវរក្សាទុកនៅផ្ទះ ។

**មាត្រា ១០:** មន្ត្រីគយ ពន្ធដារ រុក្ខាប្រមាញ់ ជលផល ក្រុមហ៊ុនចំការកៅស៊ូរដ្ឋ បរិដ្ឋាន និង ធនាគារជាតិនៃកម្ពុជា ដែលមានថ្នាក់ដូចមានចែងក្នុងមាត្រា ៩ នៃអនុក្រឹត្យនេះ មានសិទ្ធិប្រើប្រាស់អាវុធខ្លី តែក្នុងពេលចេញទៅបំពេញបេសកកម្ម ។

**មាត្រា ១១:** ចំពោះអាវុធវែង មិនអនុញ្ញាតអោយប្រើប្រាស់ជាលក្ខណៈបុគ្គលឡើយ ។ អាវុធវែងអាចប្រើប្រាស់តាមអង្គភាព សំរាប់ការពារស្ថាប័ន អង្គភាព ឬ ឃ្លាំង និង សំរាប់ចុះបំពេញបេសកកម្មនៅតាមតំបន់អសន្តិសុខ និង លំនៅដ្ឋាន នៃសមាសជិករាជរដ្ឋាភិបាលសភាជាតិ និងវរជន សំខាន់ឯទៀតដែលរាជរដ្ឋាភិបាលបានសំរេច ។

**មាត្រា ១២:** ហាមមិនអោយយកកាំភ្លើង វែង ខ្លី ចូលក្នុងរាជធានីភ្នំពេញ ហើយត្រូវទុកនៅប៉ុស្តិ៍គ្រប់គ្រងអាវុធជាតិផ្ទុះ តាមការកំណត់ដោយប្រកាសអន្តរក្រសួង របស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ និង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៣:** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ១៤:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ

ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

| | |
|---|---|
| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
| ព្រះហស្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| **នរោត្តម រណឫទ្ធិ** | **ហ៊ុន សែន** |

## ២_សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ ១៩៩៥

**សេចក្តីសំរេចលេខ ៥៣ សសរ**

**ស្តីពី**

**ការបង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយ**

**ចំពោះជនពលី—ពិការ**

* * * *

**រាជរដ្ឋាភិបាល**

–បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

–បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

–បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

–ផ្អែកតាមសភាពការណ៍ចាំបាច់ចំពោះមុខ

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការត្រួតពិនិត្យគោលនយោបាយចំពោះជនពលីពិការនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោម ÷

១–ឯកឧត្តម រដ្ឋលេខាធិការក្រសួងសង្គមកិច្ចការងារ និង អតីតយុទ្ធជន ជាប្រធាន